# ជីអំពុក

សន្លឹកព័ត៌មាន

## វិធីធ្វើជីអំពុក

### រៀបគំនរជីអំពុក

នេះជាមធ្យោបាយងាយស្រួលក្នុងការធ្វើជីអំពុក។ ដាក់សំរាមសួនច្បាររបស់លោកអ្នក ហើយនិងកាកសំណល់បន្លែចូលទៅក្នុងគំនរ។ ត្រូវប្រាកដថាលោកអ្នកដាក់សារធាតុពណ៌បៃតង និងសារធាតុពណ៌ត្នោតចូលទៅក្នុងគំនរ។ ជ្រោយជី២ដង ក្នុង១អាទិត្យ ឲ្យបានចំនួន១២អាទិត្យ។





### ធុងជីអំពុក

មានធុងសំរាប់ដាក់ជីអំពុកប្រភេទផ្សេងគ្នា ដែលលោកអ្នកអាចទិញបាន ឬលោកអ្នកអាចធ្វើដោយខ្លួនឯង។ ដាក់សារធាតុពណ៌ត្នោត និងសារធាតុពណ៌បៃតងចូលទៅក្នុងធុងដោយរៀបជាស្រទាប់។ ជ្រោយជីអំពុកជាមួយប៉ែលប្រើក្នុងសួនច្បារ រៀងរាល់២អាទិត្យម្តង។ ដាក់ឲ្យមានរន្ធនៅសងខាងគៀនធុងដើម្បីឲ្យខ្យល់អាចចេញចូល ហើយទឹកអាចហូរចេញក្រៅបាន។



### ជីអំពុកធ្វើពីពំនូកសារធាតុផ្សេងៗ

នេះគឺជាការល្អប្រសើរ ប្រសិនបើលោកអ្នកចង់ធ្វើជីអំពុកឲ្យបានច្រើន។

ពំនូកសារធាតុគឺជាគំនរធំៗ ដែលមានកំពស់២ម៉ែត្រ ទទឹង៣ម៉ែត្រ ហើយបណ្តោយមានប្រវែងតាមចិត្ត។

ត្រូវជ្រោយពំនូកសារធាតុ១ដង ក្នុង១អាទិត្យ ឬច្រើនដង ដោយប្រើត្រាក់ទ័រ។ ការធ្វើបែបនេះដើម្បីឲ្យច្បាស់ថាគ្រប់សារធាតុក្នុងពំនូកត្រូវកំដៅថ្ងៃ។ ជីអំពុកត្រូវការឲ្យក្តៅដើម្បីបំផ្លាញគ្រាប់រុក្ខជាតិ ហើយនិងសារធាតុអាក្រក់ មុននឹងលោកអ្នកដាក់វាចូលទៅក្នុងដីរបស់អ្នក។

HAWKESBURY NEPEAN CATCHMENT MANAGEMENT AUTHORITY

NSW DEPARTMENT OF PRIMARY INDUSTRIES

# ជីអំពុក

## ប្រព័ន្ធធ្វើជីអំពុក

ជ្រើសរើសយកប្រព័ន្ធជីអំពុកដែលល្អសំរាប់ចំការរបស់លោកអ្នក។

### ប្រព័ន្ធធំ

(១២ ទៅ១០០តោន)

ធ្វើជីអំពុកបានច្រើន

ចំណេញពេលវេលា ចំណេញទីកន្លែង

ផ្ទុកដោយខ្លួនឯង

ទុកឲ្យខ្យល់ចេញចូល

លោកអ្នកអាចដាក់បានគ្រប់សារធាតុកាកសំណល់របស់លោកអ្នក

ធ្វើកិច្ចការជីអំពុកជាមួយម៉ាស៊ីន

### ប្រព័ន្ធមធ្យម

(១ ទៅ១២តោន)

ប្រព័ន្ធធ្វើនៅទីកន្លែងផ្ទាល់

ផ្ទុកដោយខ្លួនឯង

ងាយស្រួលប្រើ

លោកអ្នកពុំចាំបាច់ធ្វើអ្វីច្រើន

សីតុណ្ហភាពអាចត្រួតពិនិត្យបាន

### ប្រព័ន្ធតូច

(៤០០លីត្រ)

ងាយស្រួលក្នុងការទុកដាក់

ងាយស្រួលប្រើ

ត្រូវការថាមពលបន្តិចបន្តួច

អស់ថ្លៃតិច។

## ពេលដែលត្រូវប្រើជីអំពុករបស់លោកអ្នក

### ដំណាក់កាលមុនការដាំដុះ

ជីអំពុកមានគុណភាពល្អសំរាប់ដីរបស់លោកអ្នក។ ពី៤ ទៅ៥អាទិត្យមុនដែលលោកអ្នកចាប់ផ្តើមដាំ ចូរលាយជីអំពុកជាមួយដីផ្នែកលើរបស់លោកអ្នក។ ជីអំពុកនឹងផ្តល់នូវសារធាតុជាតិណាយជ្រូហ្វឹន ដោយសន្សឹមៗទៅដល់រុក្ខជាតិរបស់លោកអ្នក ពេលណាវាចាប់ផ្តើមដុះ។

### រយៈពេលកំពុងដាំ

ពេលលោកអ្នកកំពុងដាំ ចូរដាក់បន្ថែមជីអំពុកខ្លះទៅក្នុងរណ្តៅកូនរុក្ខជាតិទើបនឹងដុះ។ ជីអំពុកទន់ នឹងជួយឲ្យកូនរុក្ខជាតិចាក់ឫសជ្រៅចូលទៅក្នុងដី។

### ការដាក់លាយជីទៅក្នុងជីអំពុក

ដាក់បញ្ចូលជីលាមកបសុបក្សី (សត្វស្លាប) ទៅក្នុងសារធាតុពណ៌បៃតងរបស់លោកអ្នក នៅពេលលោកអ្នកធ្វើជីអំពុកដើម្បីឲ្យវាក្លាយទៅជាជី។ ជីកកប់ជីអំពុកចូលទៅក្នុងដី ឬរាយជីនៅជុំវិញដំណាំរបស់លោកអ្នក ពេលណាវាដុះឡើង។

### ក្រោយពេលប្រមូលផល

បន្ទាប់ពីការប្រមូលផល ប្រើប្រាស់សារធាតុដំណាំដែលនៅសេសសល់ដើម្បីធ្វើជាជីអំពុកឲ្យបានច្រើនថែមទៀត។ នៅពេលនោះលោកអ្នកនឹងមានជីអំពុកសំរាប់ដំណាំរបស់លោកអ្នកនៅលើកក្រោយទៀត។

© NSW DPI February 2007

ដើម្បីទទួលយកព័ត៌មានបន្ថែមទៀតសូមទាក់ទង

Gosford Horticultural Institute
NSW Department of Primary Industries
Locked Bag 26 Gosford NSW 2250
ph: 02 4348 1913 fax: 02 4348 1910